**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០៣៤/១៨ រ.ប.ក អ.ជ.ប.គ.ញ

ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា និងទិសដៅការងារ ខែមេសា ឆ្នាំ២០១៨

(២៦/០២/២០១៨ - ២៥/០៣/២០១៨)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការចូលរួមអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក៏ដូចជាផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា - ៣១ ខែធ្នូ ឆ្នាំ២០១៨) របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែកុម្ភៈកន្លងទៅ យើងបានកត់សម្គាល់ពីសភាពការណ៍គ្រឿងញៀន និងអនុវត្តការងារនៅក្នុងខែមីនានេះ ទទួលបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងចំណោមបទល្មើសគ្រឿងញៀន ដែលបង្ក្រាបបានក្នុងខែមីនានេះ កត់សម្គាល់ឃើញសកម្មភាពចរាចរដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ដោយក្រុមឧក្រិដ្ឋជនពីតំបន់ត្រីកោណមាសឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជាតាមបណ្តាច្រកនៃខេត្តភាគឦសានប្រទេស បានកើតមាន ៥ ករណីធំៗ ក្នុងនោះ កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀនសហការជាមួយស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងរាជធានីភ្នំពេញ បង្ក្រាប ៤ ករណី និងស្នងការដ្ឋាននគរបាលខេត្តក្រចេះ បង្ក្រាប ១ ករណី សរុបចាប់យកមេតំហ្វេតាមីន ICE - WY ជាង ៣៧ គីឡូក្រាម និងឃាត់ខ្លួនជនសង្ស័យជាជនបរទេស ៥ នាក់ ( ឡាវ ហ្វីលីពីន នីហ្សេរីយ៉ា ) ។

ការកត់សម្គាល់នៅក្នុង ៥ ករណីធំៗខាងលើ សមត្ថកិច្ចបានចាប់យកមេតំហ្វេតាមីន ICE - WY ដល់ទៅ ៩៤% នៃចំនួនមេតំហ្វេតាមីនក្នុងខែមីនានេះ ។ ដោយឡែក ជនសង្ស័យសញ្ជាតិហ្វីលីពីន និងនីហ្សេរីយ៉ា ដែលកន្លងមក ច្រើនធ្វើ សកម្មភាពតាមផ្លូវអាកាស ក៏ត្រូវបានគេប្រើឱ្យដឹកជញ្ជូនគ្រឿងញៀនប្រភេទ ICE - WY ចូលមកកម្ពុជា តាមច្រកខាងលើនេះដែរ ។

ដោយឡែក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តតាកែវ បានចុះទៅកាប់បំផ្លាញដំណាំកញ្ឆាប្រមាណជាង ៧ ម៉ឺនដើម និងចាប់យកកញ្ឆាក្រៀម ៥ គីឡូក្រាម ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. អំពីការងារដឹកនាំ ៖

### ១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

អនុវត្តតាមការដឹកនាំ និងណែនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានបន្តដឹកនាំអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ ទទួលបានលទ្ធផលគួរកត់សម្គាល់ ។

### ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធនឹងការអនុវត្តផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តជំរុញការអនុវត្តវិធានការផ្សព្វផ្សាយអប់រំ តាមរយៈ ការរៀបចំវេទិកាតុមូល ការអប់រំផ្សព្វផ្សាយដល់សិស្ស-និស្សិត កម្មករ-ពលករ ជនចំណាកស្រុក ការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន តាមប្រព័ន្ធទូរស័ព្ទ ការបិទតាំងខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍ ការរៀបចំវេទិកាជួបវិស័យឯកជន និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរដ្ឋនិងឯកជនឱ្យមាននិរន្តរភាព ដើម្បីទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការបញ្ជូនទៅទទួលសេវាព្យាបាល, ត្រូវពង្រឹង ពង្រីកសេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវពិនិត្យស្នើសុំមូលនិធិសមធម៌ដល់អ្នកញៀនគ្រឿងញៀន ឱ្យបានទទួលសេវាពិនិត្យ និងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់គ្រឿងញៀនឡើងវិញ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន **(BLO)**, មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោលនៃកងយោធពលខេមរភូមិន្ទ ។ ទន្ទឹមនេះ ត្រូវពន្លឿននីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជាពិសេស រឿងក្តីដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិឱ្យបានឆាប់ ដើម្បីគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលា ចៀសវាងការខូចខាត ធ្លាក់ចុះតម្លៃ ឬឈានដល់បាត់បង់តម្លៃទាំងស្រុងនៃទ្រព្យសម្បត្តិទាំងនោះ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវត្រៀមរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំដែលបានធ្វើការកែសម្រួលសមាសភាពរួចហើយ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម បន្តការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីការបិទស្លាកសញ្ញា ការទុកដាក់ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសការរៀបចំភូមិ ស គ្មានគ្រឿងញៀន នៅតាមព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមក ដោយមានកិច្ចអន្តរាគមន៍នានាដែលមានលក្ខណៈពហុវិស័យ ដើម្បីធ្វើជាបទពិសោធន៍ និងការពង្រឹង ពង្រីកការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** ៥កន្លែង តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ **UNODC** បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តការកែសម្រួលមាត្រាមួយចំនួននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិ ដែលជាផលបានមកពីបទល្មើសគ្រឿងញៀន និងបន្តស្នើសុំពិនិត្យនិងសម្រេចលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ជាមួយនេះ ត្រូវធ្វើការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំ និងណែនាំខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានជួបសំណេះសំណាលនិងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំនួន ២.៣៣៥ នាក់ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងទិសដៅការងារដែលបានដាក់ចេញកាលពីខែមករា ឆ្នាំ២០១៨ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- សហការជាមួយស្ថានីយទូរទស្សន៍ NICETV អញ្ជើញតំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តប៉ៃលិន (ក្នុងនោះខេត្តកោះកុងអវត្តមាន) ធ្វើជាវាគ្មិនក្នុងកម្មវិធី បទពិសោធន៍ខ្ញុំ (Share) ក្រោមប្រធានបទ យុវជន និងគ្រឿងញៀន
- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងក្រសួងទេសចរណ៍ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ឆ្នាំ២០១៨ ។

## **១.២.** ការងារអប់រំតាមសហគមន៍

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន មានមហាជនទៅទទួលសារអប់រំចំនួន **៩២.៩០៨នាក់** ។

ក្នុងនោះ ការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តជាមួយ ៖

- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ដល់យោធិន និងថ្នាក់ដឹកនាំកងពល ប្រចាំទិសស្រុកអន្លង់វែង អ្នកចូល រួម ៥៦៣នាក់ និងទិសខេត្តឧត្តរមានជ័យ អ្នកចូលរួម ៣៥០ នាក់

- អនុញ្ញាតឱ្យសមាគមយុវជនខ្មែរ (KYA) បើកវគ្គបណ្តុះបណ្តាលនិងការសម្តែងរឿងខ្លី កម្មវិធីប្រកួត កីឡា កិច្ចពិភាក្សាពីការរៀបចំសកម្មភាពអប់រំ និងសិក្ខាសាលាស្តីពី "លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការអប់រំបង្ការគ្រឿងញៀននិងគ្រឿងស្រវឹង" នៅតាមវិទ្យាល័យ អនុវិទ្យាល័យ

- បានអនុញ្ញាតឲ្យអង្គការសប្បុរសធម៌ឡៃហ្គ័រ ស្វែងយល់បន្ថែមអំពីបញ្ហាគ្រឿងញៀន និងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន លើកទី៣ របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលរៀបចំដោយអង្គការសប្បុរសធម៌ឡៃហ្គ័រ ដែលអ្នកចូលរួម ១៨ នាក់

- បានចាត់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមធ្វើការវាយតម្លៃលើគម្រោងស្វែងរកការគាំទ្រលើកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅអាស៊ី កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៨ នៅអង្គការខាណា

- បានចាត់ថ្នាក់ដឹកនាំនិងមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ នៅសាលារបស់អង្គការសប្បុរសធម៌ឡៃហ្គ័រ

- បានចាត់មន្ត្រីជំនាញ ០១រូប ចូលរួមផ្សព្វផ្សាយស្តីពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺន បញ្ជាការដ្ឋានអង្គរក្ស អ្នកចូលរួម ៧០នាក់

- ក្រុមហ៊ុន HD&S Group Co.,LTD បានបញ្ជ្រាបខ្លឹមសារពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍ ដែលមានអ្នកចូលរួម ៧១.៥៧០ នាក់

- ក្រសួងសាធារណការនិងដឹកជញ្ជូន ស្នើក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ឱ្យណែនាំអ្នកបើកបរ សូមកុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើឱ្យមានការបិទខិតប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមរថយន្ត

- ការផ្សព្វផ្សាយឃ្លីបវីដេអូខ្លីស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Facebook

- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមីនា ឆ្នាំ២០១៨ មានការចូលអានចំនួន **៨៩,១៣៧ដង** ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ ចំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- បន្តការគាំទ្រចំពោះអង្គការដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេសដ៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត
- បន្តផ្តល់សេវាព្យាបាលជំនួស ដោយឱសថមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន) ។

### ២.២. ការព្យាបាល និងស្តារនីតសម្បទា

- បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ពង្រឹងឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញអ្នកប្រើប្រាស់ និងញៀនគ្រឿងញៀនឱ្យទៅទទួលយកការព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្ត នៅតាមសហគមន៍
- ដំណើរការសាងសង់អគាររដ្ឋបាល ១កន្លែង អគារមន្ទីរពេទ្យ អគារស្នាក់នៅ សាងសង់របង ឃ្លាំង បន្ទប់អគ្គិសនី បន្ទប់ចម្រោះទឹកស្អាត មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន BLO និងពង្រឹងសមត្ថភាពជាប្រព័ន្ធការិយាល័យ BLO កាលពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ នៅខេត្តសៀមរាប
- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមអមដំណើរក្រុមការងារអង្គការ UNODC និងតំណាងស្ថានទូតអូស្ត្រាលី ដែលអញ្ជើញមកធ្វើទស្សនកិច្ចការិយាល័យBLO បាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨
- បានចាត់មន្ត្រី ២រូប ទៅបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធអេឡិចត្រូនិច (e-Learning) នាថ្ងៃទី១៣-១៦ ខែមីនា ឆ្នាំ២០១៨ នៅខេត្តព្រះសីហនុ
- បានចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ចូលរួមការបណ្តុះបណ្តាលទ្រឹស្តីអំពីការត្រួតពិនិត្យទំនិញតាមផ្លូវអាកាស នៃកម្មវិធីត្រួតពិនិត្យកុងតឺន័រ របស់អង្គការសហប្រជាជាតិ ( UNODC ) កាលពីថ្ងៃទី១៤-២៣ ខែមីនា ឆ្នាំ២០១៨ នៅសណ្ឋាគារសាន់វេ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀនសរុប **៥៥២ ករណី** (រួមទាំងបទល្មើសប្រើប្រាស់) លើ **៦៣៨ ករណី** នៃខែកុម្ភៈ ឆ្នាំ២០១៨

- ជនសង្ស័យឃាត់ខ្លួន **១.១០២នាក់** ស្រី ១០៨នាក់ (រួមទាំងជនប្រើប្រាស់) លើ **១.៣២៧នាក់** នៃខែកុម្ភៈ ឆ្នាំ២០១៨ ។

**ជនសង្ស័យទាំងអស់មាន ៦ សញ្ជាតិគឺ :** ខ្មែរ ១.០៨៥នាក់ (ស្រី ១០៧នាក់),វៀតណាម ១១ នាក់ (ស្រី ១ នាក់), ឡាវ ២នាក់, ហ្វីលីពីន ១នាក់, នីហ្សេរីយ៉ា ២នាក់, បារាំង ១នាក់ និងជប៉ុន ១នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

**ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖**

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៤៨៥ ករណី** ឃាត់ខ្លួនជនសង្ស័យ **៩៥៣ នាក់** (ស្រី ៨៨នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៦៧ករណី** ឃាត់ខ្លួនជនសង្ស័យ **១៤៩ នាក់** (ស្រី ២០នាក់)

- **វត្ថុតាងគ្រឿងញៀនចាប់យក :** មេតំហ្វេតាមីនក្រាមម្សៅ(ICE) ៣៨ គ.ក្រ ៦៦៨ ក្រាម ៨២០ មិល្លីក្រាម, មេតំហ្វេតាមីនគ្រាប់(WY) ១គ.ក្រ ០៤០ក្រាម ៣១០មិល្លីក្រាម, កញ្ឆា ៥.០០០ ក្រាម, ដើមកញ្ឆា ៧៤.៥១៨ ដើម ។

**(មេតំហ្វេតាមីន ICE និង WY សរុបរួម ៣៩គ.ក្រ ៦០៧ ក្រាម ១៣០ មិល្លីក្រាម)**

- ទ្រព្យសម្បត្តិសំខាន់ៗ ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន រថយន្ត ៤ គ្រឿង, ម៉ូតូ ១៥២ គ្រឿង, ទូរស័ព្ទ ៤៥៧ គ្រឿង, ជញ្ជីង ២៨ គ្រឿង, ប្រាក់កម្ពុជា ៨.៥៩៣.៣០០ រៀល, ប្រាក់ថៃ ៤.៧០០ បាត, ប្រាក់អាមេរិក ៥៨៦ ដុល្លារ, ប្រាក់វៀតណាម ៩៤៥.០០០ ដុង
- ជនសង្ស័យចាប់តាមដីកា មាន ២៤ ដីកា ចាប់បានជនសង្ស័យ ២២នាក់ (ស្រី១នាក់) ។

## ៣.៣. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែមីនា ឆ្នាំ២០១៨ មាន **២៣៥ ករណី** ស្មើនឹង **២៦២ សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន **២២៧ ករណី** = **២៤៨ សំណាក** (៩៤,៦៣%) គឺ :
  - មេតំហ្វេតាមីនគ្រាប់ (WY) ១០សំណាក = ៣,៨១%
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២២៩សំណាក = ៨៧,៤០%
  - កេតាមីន ០៣សំណាក = ១,១៤%
  - កញ្ឆា ០៣សំណាក = ១,១៤%
  - MDMA ០៣សំណាក = ១,១៤%
- **សំណាកអវិជ្ជមានសារធាតុញៀន ០៨ ករណី = ១៤ សំណាក** (៥,៣៤%) ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រួតពិនិត្យសារជាតុញៀន ក្នុងតារាងទី២ និងទី៣ និងសារជាតុគីមីផ្សំក្នុងរាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងខែ មីនា ឆ្នាំ២០១៨នេះ សរុបមាន **៥៤.១៧៩១** គ.ក្រ ក្នុងនោះ ៖

- ផ្តល់អាជ្ញាបណ្ណ័និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដាប្រើប្រាស់សារធាតុគីមី ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ២៥៨.២៣១ គ.ក្រ
- ចេញអាជ្ញាប័ណ្ណ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ២៨៣.៥០០ គ.ក្រ
- នាំចូល ដោយក្រសួងសុខាភិបាល មាន ៦០ គ.ក្រ ។

### ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ៣រូប ចូលរួមសិក្ខាសាលាអាស៊ានស្តីពី កិច្ចប្រតិបត្តិការបណ្តាញឃ្លាំមើលគ្រឿងញៀនលើកទី៥ កាលពីថ្ងៃទី០៦-១០ខែមីនាឆ្នាំ២០១៨ នៅប្រទេសថៃ

- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី១៣ កាលពីថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ

- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ចូលរួមសិក្ខាសាលាអាស៊ានស្តីពីការងារស្ថិតិដំណាំគ្រឿងញៀនក្រោមគម្រោង ASEAN NARCO កាលពីថ្ងៃទី១៨-២៣ ខែមីនា ឆ្នាំ២០១៨ នៅខេត្ត ឈៀងម៉ៃ ប្រទេសថៃ ។

### ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- អគ្គលេខាធិការ និងសហការី ២រូប ចូលរួមមហាសន្និបាតស្តីពីនិរន្តរភាពនៃការអភិវឌ្ឍ ការបង្ការបទឧក្រិដ្ឋទាក់ទងការដាំដុះដំណាំគ្រឿងញៀន កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ

- អគ្គលេខាធិការ និងសហការី ២រូប ចូលរួមកិច្ចប្រជុំគណៈកម្មាធិការគ្រឿងញៀន លើកទី៦១ ទីស្នាក់ការកណ្តាលនៅអង្គការសហប្រជាជាតិ ពីថ្ងៃទី១២-១៦ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងវីយែន ប្រទេសអូទ្រីស។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- អគ្គលេខាធិការ និងសហការី ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារទេសចរណ៍ប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ និងកម្មវិធីទិវាជាតិទីក្រុងស្អាត លើកទី៦ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ

- បន្តជំរុញការអនុវត្តសកម្មភាពនៃផែនការភូមិ ស គ្មានគ្រឿងញៀន

- បន្តរៀបចំខ្លឹមសារសេចក្តីព្រាងទាក់ទងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៨

ដើម្បីអនុវត្តបន្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ (ឆ្នាំ២០១៨) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅការងារ សម្រាប់**ខែមេសា ឆ្នាំ ២០១៨** ដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. ត្រៀមសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ។

១.២. បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់ទេសចរណ៍របស់រាជធានី-ខេត្ត តាមគ្រឹះស្ថានសិក្សា និងនៅតាមបណ្តារោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងក្នុងរាជធានីភ្នំពេញ ។

១.៣. ត្រៀមចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ របស់រាជរដ្ឋាភិបាល នៅស្ថានីយទូរទស្សន៍ហង្សមាស ។

១.៤. បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ។

១.៥. បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និងNICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

១.៦. បន្តសហការជាមួយក្រុមហ៊ុន HD &S Group Co.,LTD បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍គ្មានគ្រឿងញៀន ។

១.៧. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៨. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៩. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅលើក្រុមគោលដៅជាសិស្សានុសិស្ស ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

២.១. ត្រៀមរៀបចំទទួលគណៈប្រតិភូ នៃមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់មហាក្សត្រីយានី នៃព្រះរាជណាចក្រថៃ មកធ្វើទស្សនកិច្ច និងពិភាក្សាការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅខេត្តកំពត ខេត្តព្រះសីហនុ និង រាជធានីភ្នំពេញ ។

២.២. ចាត់បញ្ជូនមន្ត្រីសហការប្រមូលទិន្នន័យការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជាឆ្នាំ២០១៧ ។

២.៣. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹងនិងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

២.៤. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៥. បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំ កែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

២.៦. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិត នៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

២.៧. ចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

៣.១. បន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនង (**BLO**) ថ្មី កម្ពុជា-វៀតណាម ចំនួន ២ នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (ខេត្តកំពត) ។

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមប្រជុំជាមួយក្រុមបេសកកម្មជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

៣.៣. ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមព្រំដែននៃច្រកទ្វារនីមួយៗ ។

៣.៤. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ តាមមេរៀនក្នុងប្រព័ន្ធ e-Learning និង CBT ។

៣.៥. ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែសមុទ្រ ។

៣.៦. ត្រៀមរៀបចំកិច្ចពិភាក្សាជាមួយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការសាលាឧទ្ធរណ៍ លើការងារប្រមូលទិន្នន័យបទល្មើសគ្រឿងញៀន ។

**៤. ការត្រួតពិនិត្យសារជាតុគីមីផ្សំ**

៤.១. បន្តការចងក្រងព័ត៌មានពាក់ព័ន្ធនឹងសារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.២. បន្តចូលរួមជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងទំនិញគ្រោះថ្នាក់។

៤.៣. ត្រៀមរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារជាតុគីមីផ្សំ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ២០១៧-២០១៨ ។

៥.២. បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា ថៃ ឡាវ រយៈពេល ២ឆ្នាំ (២០១៧ -២០១៨) ។

៥.៣. ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី កម្ពុជា-ឡាវ-វៀតណាម ដែលនឹងប្រារព្ធនៅប្រទេសឡាវ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងសហការី ៥រូប ចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការមេ៥ឆ្នាំ (២០១៩-២០២៣) នៃគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ នៅប្រទេសថៃ ។

៦.២. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមសិក្ខាសាលា ស្តីពីការវិភាគផ្លូវចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំតាមដងទន្លេមេគង្គ នៅប្រទេសវៀតណាម ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. បន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. បន្តណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

៧.៣. បន្តការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា-៣១ ខែធ្នូ ឆ្នាំ២០១៨) ។

៧.៤. ជំរុញការរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៧.៥. បន្តការរៀបចំខ្លឹមសារសេចក្តីព្រាងមាត្រាមួយចំនួន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ដែលមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស-វិរិទ្ធ**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនជាក់ អនុប្រធាន អ.ជ.ប.គ.ញ.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

"ដើម្បីជូនជ្រាប"

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ